ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត កំពង់ស្ពឺ

- សំណុំរឿងរដ្ឋប្បវេណី

លេខ ៨៣

ចុះថ្ងៃទី ២៤-០៦-២០១០

- សាលក្រម

លេខ ០២ "ឥ"

ចុះថ្ងៃទី ១២-០៥-២០១០

## នាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូង ខេត្តកំពង់ស្ពឺ បានបើក និងបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ២៦-០៤-២០១០ ដោយមានសមាសភាពដូចខាងក្រោម :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមនៃសាលាដំបូង ខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពង់ស្ពឺ

**មេធាវី**

លោក [redacted] អ្នកតំណាងដោយអាណត្តិ ចុងចម្លើយ

- ដើមចោទឈ្មោះ [redacted] កោសល្យ និងឈ្មោះ [redacted] សុខា មានទីលំនៅ ភូមិស្វាយក្រវ៉ាន់ សង្កាត់ ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្ត កំពង់ស្ពឺ ។

- ចុងចម្លើយឈ្មោះ [redacted] ជា និងប្តីឈ្មោះ [redacted] បាន មានទីលំនៅភូមិផ្សារសាមគ្គីសង្កាត់កណ្តាលជុំក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**អង្គហេតុ និងចំណុចពិចារណា**

**សាលក្រមដែលមិនទាន់ជាស្ថាពរដោយដើមចោទ**

**១. ដើមចោទនាំរឿងមកតុលាការ**

- ដើមចោទប្តឹងទាមទារប្រាក់ចំនួន ១២ ០០០ដុល្លារ( មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ដូចមាននៅក្នុងកិច្ចសន្យាខ្ចីប្រាក់កាលពីថ្ងៃទី ០១ ខែ ១២ ឆ្នាំ ២០០៨ ពីចុងចម្លើយ ការប្រាក់ ៦០០ដុល្លារ( ប្រាំមួយរយដុល្លារអាមេរិក) ក្នុង១ខែ រហូតដល់សងប្រាក់គ្រប់ចំនួន និងសុំឱ្យរឹបអូសផ្ទះ និងដីដែលដាក់បញ្ចាំ ។

- សុំទាមទារការខាតបង់ និងការយឺតយ៉ាវចំនួន ៤០០០ដុល្លារ( បួនពាន់ដុល្លារអាមេរិក) ។

- សុំឱ្យភាគីចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**២. ការអះអាងរបស់ភាគី**

- ភាគីដើមចោទឈ្មោះ [redacted] សុខា និងប្តីឈ្មោះ [redacted] កោសល្យ បានថ្លែងការណ៍ថា ដំបូងឈ្មោះ [redacted] ជា បានទៅខ្ចីប្រាក់ពីបងស្រីរបស់ខ្លួន ឈ្មោះ [redacted] សុខជា បន្ទាប់មកឈ្មោះ [redacted] សុខជា ប្រាប់ឱ្យមកជួបខ្លួន ទើបឈ្មោះ [redacted] ជា បានមកជួបខ្លួនហើយបានព្រមព្រៀងធ្វើកិច្ចសន្យាខ្ចីប្រាក់ចំនួន ១២០០០ដុល្លារ( មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ដោយព្រមព្រៀងឱ្យការប្រាក់ ៦០០ដុល្លារ( ប្រាំមួយរយដុល្លារអាមេរិក) ក្នុង១ខែ ហើយក៏បានចុះកិច្ចសន្យានៅថ្ងៃទី ០១-១២-២០០៨ ដោយមានសាក្សីមេភូមិ មេឃុំដឹងឮទៀតផង ក្រោយពីភាគីចុងចម្លើយបានទទួលប្រាក់ពីខ្លួនហើយ ភាគីចុងចម្លើយមិនបានអនុវត្តតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ០១-១២-២០០៨ ដោយមិនបង់ការប្រាក់ និងប្រាក់ដើមឱ្យខ្លួនតាមកិច្ចសន្យាខ្ចីប្រាក់រហូតមកដល់សព្វថ្ងៃនេះ ។ សំណូមពរសុំទាមទារប្រាក់ដើមចំនួន១២០០០ដុល្លារ( មួយម៉ឺនពីរ



Scanned with CamScanner

ពាន់ដុល្លាអាមេរិក) ការប្រាក់ ៦០០ដុល្លា( ប្រាំមួយរយដុល្លាអាមេរិក) ក្នុង១ខែ និងទាមទារការយឺតយ៉ាវចំនួន ៤០០០ ដុល្លា(បួនពាន់ដុល្លាអាមេរិក) ហើយបើភាគីចុងចម្លើយគ្មានប្រាក់សងទេ គឺសុំរឹបអូសផ្ទះ និងដីដែលបានដាក់បញ្ចាំ ។

- ភាគីចុងចម្លើយឈ្មោះ [redacted] ជា ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថា កូនក្តីរបស់ខ្លួនពិតជាបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១២០០០ ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ហើយព្រមព្រៀងបង់ការប្រាក់ ៦០០ ដុល្លា( ប្រាំមួយរយដុល្លាអាមេរិក) ក្នុង ១ខែ មាននៅក្នុងកិច្ចសន្យាចងការប្រាក់ចុះថ្ងៃទី ០១-១២ ២០០៨ តែកូនក្តីរបស់ខ្លួនបានអះអាងថា ក្រោយពីគាត់បានខ្ចីប្រាក់ពីដើមចោទហើយគាត់បានបង់ការប្រាក់ឱ្យទៅដើមចោទក្នុង ១ថ្ងៃ ២០ ដុល្លាអាមេរិក សរុបទាំងអស់ចំនួន ១៩២០ដុល្លា ( មួយពាន់ប្រាំរយម្ភៃដុល្លាអាមេរិក) រួចហើយ ដូច្នេះក្នុងរឿងក្តីនេះខ្លួនទទួលស្គាល់ប្រាក់ដើម១២០០០ដុល្លា( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ហើយសុំឱ្យគិតការប្រាក់ទៅតាមច្បាប់កំណត់ ដោយគិតចាប់ពីថ្ងៃទី ១៤-០២-២០០៩ ។

៣. **ចំណុចវិវាទ**

- ភាគីដើមចោទបានអះអាងថា ភាគីចុងចម្លើយមិនបានបង់ការប្រាក់ និង ប្រាក់ដើមមកឱ្យខ្លួនតាមកិច្ចសន្យាទេ តែភាគីចុងចម្លើយបានអះអាងថា ខ្លួនបានបង់ការប្រាក់ក្នុង ១ថ្ងៃ ២០ដុល្លា សរុបចំនួន ១៩២០ដុល្លា( មួយពាន់ប្រាំរយម្ភៃដុល្លាអាមេរិក)ឱ្យទៅដើមចោទហើយ ។

**សំអាងហេតុ**

- តាមសេចក្តីថ្លែងការណ៍របស់ ភាគីដើមចោទបានបញ្ជាក់ថា ខ្លួនប្តឹងទាមទារឱ្យភាគីចុងចម្លើយសងប្រាក់ដើមចំនួន ១២០០០ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) និងការប្រាក់ប្រាំភាគរយ ក្នុងចំនួនទឹកប្រាក់ដើមរយៈពេល ៦ខែ និងប្រសិនបើភាគីចុងចម្លើយ មិនមានប្រាក់សងទេ ខ្លួនសុំឱ្យរឹបអូសទ្រព្យសម្បត្តិដូចជាផ្ទះ និងដី ហើយទាមទារការយឺតយ៉ាវចំនួន ៤០០០ដុល្លា ( បួនពាន់ដុល្លាអាមេរិក) ។

- ភាគីចុងចម្លើយឈ្មោះ [redacted] ជា ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថា : ចំណុចវិវាទលើទឹកប្រាក់ដែលកូនក្តីរបស់ខ្លួនពិតជាបានបង់ឱ្យភាគីដើមចោទចំនួន ១៩២០ ដុល្លា ( មួយពាន់ប្រាំរយម្ភៃដុល្លាអាមេរិក) នោះជាការប្រាក់ដែលបានបង់តាមការព្រមព្រៀងដូចមាននៅក្នុងកិច្ចសន្យារួចហើយ ហើយខ្លួនទទួលស្គាល់ប្រាក់ដើមចំនួន ១២០០០ ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) និងសុំឱ្យគិតការប្រាក់តាមកំណត់ច្បាប់ដោយគិតចាប់ពីថ្ងៃទី ១៤-០២-២០០៩ ។

- តាមសេចក្តីថ្លែងការណ៍របស់សាក្សីឈ្មោះ [redacted] **សេរី** បានបញ្ជាក់ថា : នៅថ្ងៃទី ១០-១២-២០០៨ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាខ្ចីប្រាក់ចំនួន ១២០០០ដុល្លា( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដោយឈ្មោះ [redacted] **ជា** បានខ្ចីលុយពីឈ្មោះ [redacted] **សុខា** ដោយមានរូបខ្លួន បានចុះហត្ថលេខា ដឹងឮពីរឿងនេះ ចំណែកឯបញ្ហា ចុងចម្លើយបង់ការប្រាក់ រឺមិនបង់នោះ គឺខ្ញុំបាទមិនបានដឹងអ្វីទេ ។

- តាមសេចក្តីថ្លែងការណ៍របស់សាក្សីឈ្មោះ [redacted] **ណាន** បានបញ្ជាក់ថា : កាលពីថ្ងៃទី ០១-១២-២០០៨ បានឃើញឈ្មោះ [redacted] **ជា** និងឈ្មោះ [redacted] **បាន** ឈ្មោះ [redacted] **កោសល្យ** និងឈ្មោះ [redacted] **សុខា** បានទៅសង្កាត់ដោយមានកិច្ចសន្យាខ្ចីប្រាក់ គឺឈ្មោះ [redacted] **ជា** និងឈ្មោះ [redacted] **បាន** ខ្ចីលុយពីឈ្មោះ [redacted] **សុខា** និងឈ្មោះ [redacted] **កោសល្យ** ចំនួន ១២០០០ដុល្លា( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដោយមានដាក់បញ្ចាំប្លង់ផ្ទះ ខ្លួនក៏បានចុះហត្ថលេខាដឹងឮលើកិច្ចសន្យា នោះដែរ រីឯរឿងភាគីចុងចម្លើយ បានបង់ការប្រាក់ចំនួនប៉ុន្មាន ឱ្យទៅភាគីដើមចោទយ៉ាងម៉េចនោះ គឺខ្ញុំមិនបានដឹងទេ ។



Scanned with CamScanner

- តាមសេចក្ដីថ្លែងការណ៍របស់សាក្សីឈ្មោះ[redacted] ណារិន បានបញ្ជាក់ថា : ឈ្មោះ[redacted] ផា និងឈ្មោះ[redacted] បាន មករកខ្ចីលុយពីខ្លួននៅក្នុងអំឡុងខែ១១-២០០៨តែខ្លួនបានប្រាប់ថាខ្លួនមិនរកស៊ីចងការប្រាក់ទេ បើចង់ខ្ចីសួរប្អូនស្រីរបស់ខ្លួនឈ្មោះ[redacted] សុខា ទៅបន្ទាប់មកប្អូនស្រីខ្លួនបានព្រមឱ្យឈ្មោះ[redacted] ផា ខ្ចីលុយដោយធ្វើកិច្ចសន្យានៅ ថ្ងៃទី ០១-១២-២០០៨ ហើយប្រគល់លុយនៅថ្ងៃទី ០៣-១២-២០០៨ចំពោះភាគីចុងចម្លើយបានសង ឬបង់ការប្រាក់យ៉ាងណានោះគឺ ខ្លួនមិនបានដឹងរឿងអ្វីទេ ។

- តាមសេចក្ដីថ្លែងការណ៍របស់សាក្សីឈ្មោះ[redacted] សុជា បានបញ្ជាក់ថា : ខ្លួនមិនដែលទទួលប្រាក់ពីឈ្មោះ[redacted] ផា និងកូនរបស់ឈ្មោះ[redacted] ផា ម្ដងណាទេគ្រាន់តែបានដឹងថា ឈ្មោះ[redacted] ផា និងឈ្មោះ[redacted] បាន បានខ្ចីលុយពី ឈ្មោះ[redacted] សុខា ចំនួន ១២០០០ ដុល្លា( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) តែប៉ុណ្ណោះ ។

- តាមសេចក្ដីថ្លែងការណ៍របស់មេធាវីឈ្មោះ[redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយ បានបញ្ជាក់ថា : ចំណុចវិវាទគឺកូនក្ដីខ្លួនបានបង់ប្រាក់អស់ចំនួន ១៥២០ ដុល្លា ( មួយពាន់ប្រាំរយម្ភៃដុល្លាអាមេរិក) តែភាគីដើមចោទអះអាងថាមិនបានទទួលប្រាក់ម្ដងណាទេ ។ ខ្លួនសុំឱ្យតុលាការ ចេញសាលក្រមរបៀបមួយដើម្បីពិនិត្យ និងធ្វើកោសលវិច័យលើតួអក្សរ ឬចេញសាលក្រមសំរេចឱ្យបង់ការប្រាក់គិតចាប់ពីថ្ងៃទី ១៤-០២-២០០៩ ។

ឃើញថាអង្គហេតុប្រយោលអាចនាំឱ្យតុលាការវាយតំលៃបានថា ដើមចោទមានអត្ថិភាព នៃសិទ្ធិទាមទារចំពោះរបស់ខ្លួន ដូច្នេះសេចក្ដីសំរេចបញ្ចប់មានដូចតទៅ :

## សេចក្ដីសំរេចបញ្ចប់

១- បង្គាប់ឱ្យឈ្មោះ[redacted] ផា និងឈ្មោះ[redacted] បាន សងប្រាក់ដើមចំនួន១២០០០ដុល្លា( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ឱ្យទៅភាគីដើមចោទឈ្មោះ[redacted] សុខា និងឈ្មោះ[redacted] កោសល្យ និងការប្រាក់ ៥ភាគរយ ក្នុង ១ឆ្នាំ គិតចាប់ពីថ្ងៃទី ១៤-០២-២០០៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន និងការយឺតយ៉ាវចំនួន ៦ ០០០០០០ រៀល( ប្រាំមួយលានរៀល) គត់ ។ ករណីគ្មានប្រាក់សង ត្រូវរឹបអូសផ្ទះ និងដី ដែលបានដាក់បញ្ចាំក្នុងកិច្ចសន្យាចងការប្រាក់ ។

២- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចុងចម្លើយ ។

៣- សាលក្រមនេះទាញហេតុផ្ទាល់មាត់នៅថ្ងៃទី ២៦-០៤-២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១២-០៥-២០១០ ។

៤- បើភាគីណាមិនសុខចិត្ត និងសាលក្រមនេះមានសិទ្ធិប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលអនុសារសាលក្រមនេះ ។

ហត្ថលេខា និងត្រា

ចៅក្រម [redacted]

---

អនុសារសាលក្រមនេះមានអនុភាពដូចមូលសាលក្រមដែរ ។

...ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១០

ក្រឡាបញ្ជី

[redacted]

បានឃើញ

...ថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០១០

ចៅក្រម

[redacted]

៣